# អស់ឱកាស

(បទពំនោល)

ពេលបងឃ្លាតឃ្លាទៅឆ្ងាយ ខ្ញុំនៅនឹកស្តាយ ខ្វល់ខ្វាយចិត្តពុំសាយសះ។
ពាក្យពិតក្នុងចិត្តច្រើនណាស់ ចង់ថ្លែងឱ្យច្បាស់ តែបងគ្មានឱកាសស្តាប់។
ពេលនេះសល់ត្រឹមឈឺចាប់ ហឫទ័យអួអាប់ ពុំដឹងស្រែកប្រាប់នរណា។
កាលបងនៅនិត្យកាយា ខ្ញុំកាន់ទោសា ចិន្តាខ្វះការអភ័យ។
លុះបងឃ្លាតឆ្ងាយហើយនៃ ទើបនឹកមមៃ ចង់ជួបចង់ស្តីចរចា។
បានត្រឹមចង់បង់អសារ ព្រោះគ្មានពេលណា បងអាចវិលសាជាថ្មី។
ទោះខ្ញុំយំលិចផែនដី ពុំអាចកែខៃ ទាញថ្ងៃនោះវិលវៃហោង។
ឥឡូវដល់វេនខ្ញុំម្តង សោយសោកកន្ទង់ យំសុំឱ្យបងអភ័យ៕



**ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី**